គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិុន

PG 限额供资银行

PG DEVELOPMENT MICROFINANCE PLC.

# របាយការណ៍ប្រចាំឆ្នាំ

# ២០២០

# មាតិកា


បេសកកម្ម និងទស្សនៈវិស័យ....................................................................i-ii
ប្រវត្តិសង្ខេបរបស់ស្ថាប័ន.......................................................................iii
ព័ត៌មានអំពីស្ថាប័ន.................................................................................v
ពាណិជ្ជកម្មសង្ខេប.............................................................................vi-x
រចនាសម្ព័ន្ធគ្រប់គ្រង..............................................................................xi
អភិបាលកិច្ចរបស់ស្ថាប័ន...................................................................xii-xvi


## របាយការណ៍ហិរញ្ញវត្ថុបានធ្វើសវនកម្ម


របាយការណ៍របស់ក្រុមប្រឹក្សាភិបាល...................................................១-៣
របាយការណ៍របស់សវនករឯករាជ្យ......................................................៤-៨


## របាយការណ៍ហិរញ្ញវត្ថុ


របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ.......................................................៩
របាយការណ៍ស្តីពីលទ្ធផលពេញលេញ.....................................................១០
របាយការណ៍ស្តីពីបម្រែបម្រួលមូលធន....................................................១១
របាយការណ៍ស្តីពីលំហូរសាច់ប្រាក់..................................................១២-១៣
កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ...........................................១៤-៦៣
ព័ត៌មានហិរញ្ញវត្ថុបន្ថែម និងកំណត់សម្គាល់ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា..............i-v

# បេសកកម្ម និងទស្សនៈវិស័យ

## បេសកកម្ម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិុន ម.ក គឺជាគ្រឹះស្ថានហិរញ្ញវត្ថុមួយដែលផ្តល់នូវសេវាហិរញ្ញវត្ថុខ្នាតតូច និងមធ្យម ដែលជួយទ្រទ្រង់ដល់សាធារណៈជនឱ្យមានជីវភាពរស់នៅកាន់តែប្រសើរឡើងតាមរយៈការផ្តល់កម្ចី ដោយមានអត្រាការប្រាក់សមរម្យ និងសេវាកម្មឆាប់រហ័សជូនទៅដល់អតិថិជនសហគ្រាសធុនតូច និងមធ្យមនៅទីក្រុង និងតំបន់ជនបទ។






# ទស្សនៈវិស័យ

ដឹកនាំគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិន ម.ក ក្លាយទៅជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុជំបូងគេ របស់អតិថិជនដែលផ្តល់ភាពងាយស្រួល និងធ្វើពិពិធកម្មផ្នែកសេវាកម្មហិរញ្ញវត្ថុនៅកម្ពុជា។



# ប្រវត្តិសង្ខេបរបស់ស្ថាប័ន




(ទិន្នន័យគិតត្រឹមខែធ្នូ ឆ្នាំ២០២០)

**ការិយាល័យកណ្តាល និងសាខា**

១

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបម៉ិន ម.ក គឺជាគ្រឹះស្ថានហិរញ្ញវត្ថុដែលបានបង្កើតឡើងនាដើមឆ្នាំ២០១៧ ដោយបានចុះបញ្ជីពាណិជ្ជកម្មលេខ ០០០២៤៨៩៦ នាថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ និងទទួលបានអាជ្ញាប័ណ្ណប្រតិបត្តិការហិរញ្ញវត្ថុលេខ ម.ហ ៨៤ ចុះថ្ងៃទី ១១ ខែសីហា ឆ្នាំ២០១៧ ពីធនាគារជាតិ នៃកម្ពុជា។ គ្រឹះស្ថានបានបង្កើតឡើងក្នុងគោលបំណងជួយសម្រួលនូវតម្រូវការហិរញ្ញវត្ថុដល់ប្រជាពលរដ្ឋទូទៅដែលពុំមានលទ្ធភាពគ្រប់គ្រាន់ និងមានតម្រូវការក្នុងការស្វែងរកប្រភពទុនដើម្បីបង្កើត និងពង្រីកអាជីវកម្មរបស់ខ្លួន។


គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិន
PG 限额供资银行
PG DEVELOPMENT MICROFINANCE PLC.

# ព័ត៌មានអំពីគ្រឹះស្ថាន

| | |
|---|---|
| គ្រឹះស្ថាន | ៖ **គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិន ម.ក** |
| ចុះបញ្ជីពាណិជ្ជកម្មលេខ | ៖ ០០០២៤៨៩៦ |
| ទីស្នាក់ការចុះបញ្ជី | ៖ ផ្ទះលេខ ២០អឺ០ ផ្លូវលេខ ១៧៨ ភូមិ១២ សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា<br>ទូរស័ព្ទ៖ (០៩៨) ៩៩៩ ១១១/ ៩៩៩ ៦១១<br>អ៊ីម៉ែល៖ **info@pgdevelopmentbank.com** |
| កាលបរិច្ឆេទដំណើរការអាជីវកម្ម | ៖ ថ្ងៃទី២៥ ខែមេសា ឆ្នាំ២០១៧ |
| សវនករខាងក្រៅ | ៖ ក្រូវ (ខេមេច) ឯ.ក |

# ពាណិជ្ជកម្មសង្ខេប

## ចំណាប់អារម្មណ៍របស់ប្រធានក្រុមប្រឹក្សាភិបាល



ប្រធាន
ក្រុមប្រឹក្សាភិបាល
លោក ម៉ែន សុខចំរើន

ប្រទេសកម្ពុជាមានសន្តិភាព ស្ថិរភាព និងកំណើនសេដ្ឋកិច្ចប្រកបដោយនិរន្តរភាពទើបធ្វើឲ្យមានការកើនឡើងគួរឲ្យកត់សម្គាល់នូវចំនួនគ្រឹះស្ថានហិរញ្ញវត្ថុក្នុងឆ្នាំ២០២០ ដែលបច្ចុប្បន្នមានធនាគារពាណិជ្ជ ចំនួន៤៨ ធនាគារឯកទេសចំនួន១៣ គ្រឹះស្ថាមីក្រូហិរញ្ញវត្ថុ ចំនួន៨១ គ្រឹះស្ថានឥណទានជនបទ២៤៦ និងក្រុមហ៊ុនភតិសន្យាហិរញ្ញវត្ថុ១៥។

យើងខ្ញុំសូមស្វាគមន៍ចំពោះបទប្បញ្ញត្តិថ្មីៗ ដែលបានដាក់ចេញដោយធនាគារជាតិ នៃកម្ពុជា ដែលផ្តោតលើការឆ្លើយតបទៅនឹងតម្រូវការកាត់បន្ថយហានិភ័យ ការពារផលប្រយោជន៍របស់ភាគីពាក់ព័ន្ធហើយជាពិសេស ដើម្បីពង្រឹងការការពារអតិថិជនក្នុងចំណោមយន្តការជាច្រើនផ្សេងទៀតដែលមានគោលដៅល្អបំផុត ដើម្បីធានាកំណើនប្រកបដោយនិរន្តរភាពនៅក្នុងវិស័យហិរញ្ញវត្ថុ។ ធនាគារពិភពលោកបានព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជា៤.៣% រីឯធនាគារអភិវឌ្ឍន៍អាស៊ីបានព្យាករណ៍ដូចគ្នាលើកំណើនសេដ្ឋកិច្ចដែលកើនឡើង ៤% សម្រាប់ឆ្នាំ២០២១ ដោយមូលហេតុនៃការធ្លាក់ចុះនូវសេដ្ឋកិច្ចឆ្នាំ២០២០ប្រមាណ ៣.១%។ កំណើននេះបន្តរីកចម្រើនក្នុងល្បឿនមួយដ៏រឹងមាំ ដោយសារការជម្រុញនាំចេញទៅកាន់ទីផ្សារអាស៊ាន សហរដ្ឋអាមេរិក និងសហភាពអឺរ៉ុប អំណោយផលនៃអាកាសធាតុ និងការគាំទ្រលើគោលនយោបាយសារពើពន្ធ។ បន្ថែមពីនេះទៅទៀត ប្រទេសចិនបាននឹងកំពុងក្លាយជាទីផ្សារដ៏សំខាន់មួយសម្រាប់ផលិតផលកសិកម្មរបស់ប្រទេសកម្ពុជា។

ចំពោះទស្សនវិស័យឆ្នាំ២០២១ វិញ បើយោងតាមរបាយការណ៍របស់ធនាគារជាតិនៃកម្ពុជា ស្តីពីការព្យាករណ៍កំណើនសេដ្ឋកិច្ចកម្ពុជា គឺនៅរក្សាកំណើនស្ថិរភាពក្នុងរង្វង់ប្រហែល ៣.៥% ក្នុងឆ្នាំ២០២១ ដោយសារកំណើនការវិនិយោគក្នុងតំបន់ វិស័យកសិកម្ម វិស័យកម្មន្តសាល វិស័យទេសចរណ៍ សំណង់ និងអចលនទ្រព្យ និងការបន្តទទួលបានប្រព័ន្ធអនុគ្រោះពន្ធ។ វិស័យទាំងអស់នេះរំពឹងថានឹងបន្តរីកចម្រើនថែមទៀត។

ទោះបីជាយ៉ាងណាសេដ្ឋកិច្ចកម្ពុជា ក៏ប្រឈមនឹងហានិភ័យមួយចំនួននៃការរីករាលដាលនៃជំងឺកូវីដ-១៩ ការកើនឡើងការប្រកួតប្រជែងនៅលើទីផ្សារអន្តរជាតិដោយសារប្រទេសមួយចំនួនដែលនាំចេញផលិតផលដូចកម្ពុជាទទួលបានកាអនុគ្រោះពន្ធ និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីជាមួយប្រទេសដែលជាទីផ្សារនាំចេញរបស់កម្ពុជា ការធ្លាក់ចុះចំណូលគ្រួសារ ការថយចុះល្បឿនកំណើនលើវិស័យសំណង់ និងអចលនទ្រព្យ និងការប្រែប្រួលអាកាសធាតុដែលអាចបន្ថយកំណើនក្នុងវិស័យកសិកម្ម ការធ្លាក់ចុះនៃវិស័យ ទេសចរណ៍ ការថយចុះការផ្គត់ផ្គង់វត្ថុធាតុដើម ដល់វិស័យកាត់ដេរ វិស័យសេវាកម្ម និងបដិសណ្ឋារកិច្ច និងការប្រកួតប្រជែងរបស់កម្ពុជានៅមានកម្រិត។ ក្នុងដំណាក់កាលនេះ យើងពិបាកក្នុងការទស្សន៍ទាយពីផលប៉ះពាល់ទៅលើកំណើនក្នុងរយៈពេលខ្លី និងរយៈពេលវែង។

ជាចុងក្រោយនេះ យើងខ្ញុំសូមសម្តែងនូវការដឹងគុណដល់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ធនាគារជាតិនៃកម្ពុជា និយ័តករ ព្រមទាំងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដែលតែងតែជួយគាំទ្រ និងប្រឹងប្រែងអភិវឌ្ឍឧស្សាហកម្មហិរញ្ញវត្ថុកម្ពុជា ពិសេសក្នុងវិស័យគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុតែម្តង។

# ចំណាប់អារម្មណ៍របស់អគ្គនាយិកា



**អគ្គនាយិកា**

លោកស្រី ង៉ូវ វួចងីម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឱវេឡុបមិន ម.ក កសាង និងផ្តល់ទំនុកចិត្ត និងតែងតែមានការទទួលខុសត្រូវខ្ពស់ចំពោះអតិថិជន។ តាមរយៈការផ្តល់សេវាកម្មឥណទានជូនប្រជាពលរដ្ឋជាអតិថិជនគោលដៅរួមមាន កសិករ អាជីវករ អាជីវកម្មខ្នាតតូចបំផុត ខ្នាតតូច និងមធ្យម គ្រឹះស្ថាន នឹងបន្តកសាងទំនាក់ទំនងដ៏រឹងមាំ និងពោរពេញទៅដោយភាពជឿជាក់។

គ្រឹះស្ថានផ្តោតការយកចិត្តទុកដាក់ខ្ពស់ក្នុងការកែលម្អប្រសិទ្ធិភាពប្រតិបត្តិការ ការពង្រឹងការត្រួតពិនិត្យផ្ទៃក្នុងផ្នែកលើធនធាន និងការអនុវត្តជាក់ស្តែង ការគ្រប់គ្រងហានិភ័យ និងការពង្រឹងគោលនយោបាយគ្រប់គ្រងអភិវឌ្ឍគ្រឹះស្ថាន។ ការត្រួតពិនិត្យវាយតម្លៃជាប្រចាំលើការងារគ្រប់គ្រងអាជីវកម្ម ជាការទទួលខុសត្រូវរបស់គណៈគ្រប់គ្រង ដើម្បីសម្រេចបានទៅតាមគោលដៅរបស់គ្រឹះស្ថាន។

គ្រឹះស្ថានមិនមែនផ្តោតទៅលើតែគោលដៅប្រាក់ចំណេញ ការលើកកម្ពស់ជីវភាពរស់នៅរបស់អតិថិជន និងសហគមន៍ជាបេសកកម្មសំខាន់ដែលគ្រឹះស្ថានតែងតែធ្វើការយកចិត្តទុកដាក់ជាគោលដៅអាទិភាព។ ជាមួយគ្នាផងដែរគ្រឹះស្ថានព្យាយាមខិតខំដើម្បីចូលរួមចំណែកក្នុងការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ក៏ដូចជាសេដ្ឋកិច្ចកម្ពុជាឆ្ពោះទៅរកការរីកចម្រើនមួយកម្រិតបន្ថែមទៀត។

គ្រឹះស្ថាននឹងបន្តកិច្ចខិតខំប្រឹងប្រែងឆ្លើយតបទៅនឹងការអនុវត្តនូវបទប្បញ្ញត្តិថ្មីៗ ដែលបានដាក់ចេញដោយធនាគារជាតិ នៃកម្ពុជា នឹងតម្រូវការកាត់បន្ថយហានិភ័យ និងតម្រូវការជាពិសេសក្នុងការការពារផលប្រយោជន៍របស់អតិថិជនជាពិសេសក្នុងអំឡុងពេលនៃការឆ្លងរីករាលដាលនៃជំងឺកូវីដ-១៩។

ដើម្បីទទួលបាននូវគុណភាពសេវាកម្ម គ្រឹះស្ថានបានរៀបចំបណ្តុះបណ្តាលបុគ្គលិកទៅតាមជំនាញវិជ្ជាជីវៈ និងប្រកបដោយគុណវុឌ្ឍ ការទំនាក់ទំនងរវាងក្រុមបុគ្គលិកគ្រប់ជាន់ថ្នាក់ និងអតិថិជន ការចែករំលែកបទពិសោធន៍ល្អៗ ដល់ក្រុមការងារផ្ទាល់ ដើម្បីបម្រើសេវាកម្មជូនអតិថិជនប្រកបដោយប្រសិទ្ធិភាព។

គ្រឹះស្ថានប្រកាន់ខ្ជាប់នូវគុណតម្លៃ និងកិត្តិនាមជាកត្តាជំរុញសំខាន់ ហេតុនេះហានិភ័យកេរ្តិ៍ឈ្មោះត្រូវបានគ្រប់គ្រងបានយ៉ាងល្អប្រសើរ។ ការបង្កើតនូវបរិយាកាសការងារដែលមានភាពល្អប្រសើរ ការបណ្តុះបណ្តាលប្រកបដោយជំនាញវិជ្ជាជីវៈពិតប្រាកដ ក៏ជាមូលដ្ឋានរីកចម្រើនរបស់គ្រឹះស្ថាន ហើយក៏ជាផ្នែកមួយក្នុងការចូលរួមយ៉ាងសំខាន់ក្នុងការអភិវឌ្ឍធនធានមនុស្ស ក៏ដូចជាសេដ្ឋកិច្ចនៅក្នុងប្រទេសកម្ពុជា។

ក្នុងនាមអគ្គនាយិកា នៃគ្រឹះស្ថាន ភីជី ឱវេឡុបមិន ម.ក នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះប្រធានក្រុមប្រឹក្សាភិបាល និងភាគទុនិកទាំងអស់ នូវការប្រឹក្សាយោបល់ ការតម្រង់ទិស ការគាំទ្រ និងការណែនាំ ឈានទៅរកការសម្រេចបាននូវសមិទ្ធផលល្អៗកន្លងមកនេះ។ នាងខ្ញុំក៏សូមឆ្លៀតឱកាសនេះ សូមថ្លែងអំណរគុណដល់រាជរដ្ឋាភិបាលកម្ពុជា ធនាគារជាតិ នៃកម្ពុជា សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងដៃគូពាក់ព័ន្ធទាំងអស់ ដែលតែងតែយកចិត្តទុកដាក់ខ្ពស់ក្នុងការការពារ និងអភិវឌ្ឍវិស័យហិរញ្ញវត្ថុនៅប្រទេសកម្ពុជាឱ្យមានការរីកចម្រើន។

# ភាគទុនិក

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិន ម.ក

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិន ម.ក ត្រូវបានគ្រប់គ្រងដោយភាគទុនិកជនជាតិខ្មែរ ហើយភាគទុនិកទាំងអស់មានចំនួនពីររូប គ្រប់គ្រងភាគហ៊ុន ១០០% របស់គ្រឹះស្ថាន។

### ភាគហ៊ុន

**USD ១,៨00,000.00**

៦០%

**USD ១,២00,000.00**

៤០%

### សរុប

**USD ៣,000,000.00**

១០០%

# សង្ខេបសមិទ្ធិផលហិរញ្ញវត្ថុរបស់ស្ថាប័ន

| លទ្ធផលប្រតិបត្តិការ | ៣១ ធ្នូ ២០២០ | ៣១ ធ្នូ ២០១៩ |
|---|---|---|
| ប្រាក់ចំណេញមុនដកពន្ធ | (១២១,៤៦៨) | (១២៣,០៤៦) |
| ប្រាក់ចំណេញសុទ្ធសម្រាប់ការិយបរិច្ឆេទ | (១២២,២៧៨) | (១២៣,៥៦៧) |

| ទិន្នន័យហិរញ្ញវត្ថុសំខាន់ៗនាចុងឆ្នាំ | | |
|---|---|---|
| សរុបទ្រព្យសកម្ម | ២,៥៦២,៤៧៥ | ១,៦៧៨,៨៦៨ |
| ឥណទាននិងបុរេប្រទាន- សុទ្ធ | ៥០០,១០៨ | ៥៣៩,១៣៨ |
| ភាគហ៊ុនទូទៅ | ៣,០០០,០០០ | ២,០០០,០០០ |
| មូលនិធិម្ចាស់ហ៊ុន | ១,៥៣១,២៤៤ | ១,៦៥៣,៥២២ |

| អនុបាតហិរញ្ញវត្ថុ | | |
|---|---|---|
| ការបង្វិលចំណូលលើទ្រព្យសកម្ម | -៤.៧៤% | -៧.៣៦% |
| ការបង្វិលចំណូលលើមូលនិធិម្ចាស់ហ៊ុន | -៧.៩៣% | -៧.៤៧% |
| មូលនិធិផ្ទាល់ធៀបនិងទ្រព្យសកម្មសរុប | ៥៩.៧៦% | ៩៨.៤៩% |
| អនុបាតសាធនភាព | ៥២៥.៦២% | ៣០០.៧៣% |

## ការប្រតិបត្តិតាមគោលការណ៍ និងបទប្បញ្ញត្តិរបស់ធនាគារជាតិ នៃកម្ពុជា

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិន ម.ក តែងតែប្រតិបត្តិទៅតាមបទប្បញ្ញត្តិ សារាចរណែនាំ សេចក្តីណែនាំ និងប្រកាសនានារបស់ធនាគារជាតិ នៃកម្ពុជា ដើម្បីឆ្លើយតបទៅនឹងតម្រូវការជាក់ស្តែងរបស់អាជ្ញាធរមានសមត្ថកិច្ច។ ការធ្វើការវាយតម្លៃច្បាប់ និងប្រកាសដែលពាក់ព័ន្ធជាកាតព្វកិច្ចចាំបាច់របស់គណៈគ្រប់គ្រងគ្រឹះស្ថាន ហើយនឹងត្រូវឆ្លើយតបឱ្យបានទាន់ពេលវេលា និងប្រកបដោយប្រសិទ្ធិភាពខ្ពស់។ ទន្ទឹមនឹងគ្នានេះដែរគ្រឹះស្ថាននឹងប្តេជ្ញាចិត្តយ៉ាងមុតមាំ ក្នុងការបន្តគោរពតាមយ៉ាងខ្ជាប់ខ្ជួននូវរាល់សារាចរណែនាំ ប្រកាស និងបទប្បញ្ញាតិថ្មីៗ ដែលចេញផ្សាយដោយធនាគារជាតិ នៃកម្ពុជា។

## សេចក្តីថ្លែងអំណរគុណ

អភិបាល របស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិន ម.ក យើងបានប្តេជ្ញារក្សានូវស្តង់ដាខ្ពស់ក្នុងការអនុវត្ត អភិបាលកិច្ចរបស់ខ្លួន ព្រមទាំងជំហរ នៃកិច្ចប្រតិបត្តិអាជីវកម្មដ៏រឹងមាំក្នុងគោលដៅធានាឱ្យបាននូវនិរន្តរភាព នៃការវិវត្តន៍ ការអភិវឌ្ឍរបស់គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ និងការពារផលប្រយោជន៍ចំពោះភាគីដែលពាក់ព័ន្ធទាំងអស់ ព្រមទាំងដាក់ចេញនូវបទប្បញ្ញត្តិ និងបទបញ្ជានានា ដើម្បីដឹកនាំបុគ្គលិកទាំងអស់ឆ្ពោះទៅកាន់ការរីកចម្រើន និងអភិវឌ្ឍ ក្នុងឥរិយាបថដែលប្រកបដោយក្រមសីលធម៌។

យើងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា គ្រឹះស្ថាននឹងចូលរួមចំណែកយ៉ាងសកម្មក្នុងការអភិវឌ្ឍទាំងសេដ្ឋកិច្ច និងសង្គមកិច្ច នៃព្រះរាជាណាចក្រកម្ពុជា ដើម្បីជួយលើកតម្កើងជីវភាពរស់នៅរបស់អតិថិជនឱ្យមានភាពល្អប្រសើរឡើងនាថ្ងៃអនាគត។

ជាទីបញ្ចប់ តាងនាមឱ្យគណៈគ្រប់គ្រង និងបុគ្គលិកទាំងអស់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល ធនាគារជាតិ នៃកម្ពុជា អាជ្ញាធរគ្រប់លំដាប់ថ្នាក់ និងអតិថិជនទាំងអស់ដែលបានផ្តល់ទំនុកចិត្តគាំទ្រ និងធ្វើកិច្ចសហប្រតិបត្តិការដល់ដំណើរការប្រតិបត្តិការរបស់គ្រឹះស្ថាន ភីជី ឌីវេឡុបមិន ម.ក។

# រចនាសម្ព័ន្ធគ្រប់គ្រង



# អភិបាលកិច្ចរបស់គ្រឹះស្ថាន

## ផលិតផល និងសេវាកម្ម

### ផលិតផល

ដោយមើលឃើញពីតម្រូវការរបស់ប្រជាពលរដ្ឋ ក្នុងការស្វែងរកប្រភពទុនដើម្បីពង្រីក និងទ្រទ្រង់មុខរបរអាជីវកម្មរបស់ពួកគាត់ឱ្យកាន់តែមានភាពល្អប្រសើរ និងរីកចម្រើនស្របតាមទីផ្សារបច្ចុប្បន្នមានការកើនឡើង គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិន ម.ក យើងខ្ញុំបានផ្តល់នូវសេវាប្រាក់កម្ចីដែលអាចបត់បែនទៅតាមតម្រូវការជាក់ស្តែងរបស់អតិថិជន ទំហំសាច់ប្រាក់ ពេលវេលានៃការសងត្រឡប់មានរយៈពេលវែង និងរបៀបនៃការសងមានច្រើនបែបហើយអាចជ្រើសរើសរូបិយប័ណ្ណជាប្រាក់រៀល ឬជាដុល្លារអាមេរិក។






## សេវាកម្ម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិន ម.ក បានយកចិត្តទុកដាក់លើសេវាកម្មអតិថិជនរក្សានូវទំនាក់ទំនងយ៉ាងល្អជិតស្និទ្ធ ពោរពេញដោយភាពរួសរាយញញឹមរាក់ទាក់ប្រកបដោយក្រមសីលធម៌ និងវិជ្ជាជីវៈ ការងារដើម្បីធានាបាននូវសេវាល្អឥតខ្ចោះ។



## ក្រមសីលធម៌អាជីវកម្ម

គ្រឹះស្ថានបានដាក់ចេញនូវបទបញ្ញាទាំងឡាយ ដើម្បីដឹកនាំបុគ្គលិកទាំងអស់ឆ្ពោះទៅកាន់ឥរិយាបថ ដែលប្រកបដោយក្រមសីលធម៌ ដោយផ្អែកទៅលើគោលការណ៍សំខាន់ៗ ដូចជា៖

- គ្មានភាពរើសអើងគ្នា
- ជៀសវាងការធ្វើឱ្យប៉ះទង្គិចដល់ផលប្រយោជន៍គ្រឹះស្ថាន
- សមភាពចំពោះបុគ្គលិក និងអតិថិជនគ្រប់រូប
- ការរក្សានូវការសម្ងាត់ នៃទិន្នន័យរបស់គ្រឹះស្ថាន និងអតិថិជន
- តម្លាភាព នៃការផ្តល់សេវាកម្មជូនអតិថិជន លើកម្រៃសេវាផ្សេងៗ
- ជៀសវាងនូវការកេណ្ឌប្រយោជន៍ផ្ទាល់ខ្លួនតាមរយៈប្រតិបត្តិការរបស់គ្រឹះស្ថាន



## ទស្សនៈវិស័យរបស់ស្ថាប័ន

- ផ្តល់ជូននូវសេវាកម្មដ៏ប្រសើរ និងមានប្រសិទ្ធិភាព
- ទំនាក់ទំនងល្អ និងមានភាពស្មោះត្រង់ចំពោះអតិថិជន និងបុគ្គលគ្រប់រូប
- ជំរុញឲ្យបុគ្គលិកសកម្ម និងមានលក្ខណៈល្អប្រពៃ តាមរយៈការបង្កើនប្រាក់បៀវត្ស
- អត្ថប្រយោជន៍បន្ថែម និងរៀបចំពិធីជប់លៀង
- ពង្រឹងការបណ្តុះបណ្តាលបុគ្គលិកក្នុងផ្នែកថ្មីៗ
- ជំរុញឱ្យមានវិន័យល្អ
- ផ្តល់ជូននូវសេវាថ្មីៗ សំរាប់អតិថិជនយើង
- ការផ្តល់សេវាកម្មឈានមុខគេ
- ការពង្រីកនូវតំបន់ប្រតិបត្តិការដែលមានសក្តានុពល
- សិក្សាស្រាវជាវអ្វីដែលថ្មី ហើយនិងសិក្សាអំពីការគ្រប់គ្រងហានិភ័យ

## ការគ្រប់គ្រងហានិភ័យ

ការគ្រប់គ្រងហានិភ័យជាចំណុចសំខាន់ដែលគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបម៉ិន ម.ក កំពុងយកចិត្តទុកដាក់យ៉ាងខ្លាំង ពីព្រោះវាជាកត្តានាំឱ្យគ្រឹះស្ថានទាំងមូលឈានទៅរកភាពជោគជ័យ។ ទន្ទឹមនឹងនេះគ្រឹះស្ថាន មានគោលការណ៍ចំបងមួយគឺ ទប់ស្កាត់ជាមុននូវហានិភ័យទាំងឡាយដែលអាចកើតមានឡើងចំពោះគ្រឹះស្ថាន ដោយធ្វើការកំណត់នូវវិធានការ និងការបែងចែកការទទួលខុសត្រូវខ្ពស់ប្រកបដោយភាពឯករាជ្យ ម្ចាស់ការតាមផ្នែកនីមួយៗ។ គ្រឹះស្ថាន នឹងកំណត់យកយុទ្ធសាស្ត្រដ៏សមស្របដើម្បីដោះស្រាយ និងកាត់បន្ថយនូវកម្រិតហានិភ័យដែលប្រឈមទាំងនោះ ដូចជា៖ ការទទួលយកការដោះស្រាយ ការផ្ទេរ និងការបញ្ចៀសជាដើម ហើយគ្រឹះស្ថាននឹងបន្តធ្វើការពិនិត្យដើម្បីប្រាកដថាហានិភ័យទាំងនោះត្រូវបានគ្រប់គ្រងនិងដោះស្រាយ។

នាយកដ្ឋានសវនកម្ម និងនាយកដ្ឋានប្រតិបត្តិតាមមានតួនាទីសំខាន់ក្នុងការកំណត់រកនូវហានិភ័យ រួចធ្វើការវាយតម្លៃ នូវភាពសមស្រប នឹងផលប៉ះពាល់នៃហានិភ័យដែលកើតមានឡើងហើយត្រូវធ្វើការគ្រប់គ្រង និងដោះស្រាយឱ្យបានទាន់ពេល។ ការត្រួតពិនិត្យជាប្រចាំដើម្បីវាយតម្លៃជាពិសេសនូវលទ្ធភាពដែលអាចកើតមានឡើង ហើយកំណត់យុទ្ធសាស្ត្រសមស្រប ឬផែនការសកម្មភាពថ្មីដើម្បីកាត់បន្ថយហានិភ័យទាំងនោះប្រកបដោយប្រសិទ្ធិភាពខ្ពស់។



## គោលដៅអាជីវកម្ម

គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឱវឡេបមិន ម.ក បានបន្តជំហរដ៏ថេរមួយក្នុងការគ្រប់គ្រងរចនាសម្ព័ន្ធដើម្បីពង្រឹងដល់ផលប្រយោជន៍ស្ថាប័ន បង្កើត និងបន្តការណែនាំការអនុវត្តន៍សេវាកម្មចាត់ទុកអតិថិជនជាចំបង បន្តពង្រឹងការរីកចម្រើនជាចំបងរបស់ខ្លួនដោយផ្តល់កម្ចីដល់អតិថិជន។ ក្នុងនោះផងដែរ គ្រឹះស្ថានមានផែនការក្នុងបន្តការផ្តោតការយកចិត្តទុកដាក់លើការពង្រីកការផ្តល់នូវកញ្ចប់ប្រាក់កម្ចីដោយឈរលើភាពជាដៃគូហិរញ្ញវត្ថុចម្បងសំរាប់ការរីកចម្រើនរបស់អតិថិជន។

## អភិបាលកិច្ច

ដើម្បីពង្រឹងនូវរចនាសម្ព័នគ្រប់គ្រង និងជាការឆ្លើយតបជាមួយនឹងសេចក្តីតម្រូវនៃច្បាប់ និងបទប្បញ្ញត្តិចេញដោយធនាគារជាតិនៃកម្ពុជា យើងបានកំពុងនឹងជ្រើសរើសនិងស្វែងរកនូវបុគ្គលិកប្រកបដោយបទពិសោធន៍ និងសមត្ថភាព សំរាប់ផ្នែកសវនកម្មផ្ទៃក្នុងនិងអនុលោមភាព។ ហើយជាបណ្តើរៗគោលការណ៍សំរាប់ការត្រួតពិនិត្យផ្ទៃក្នុង និងប្រឆាំងការសម្អាតសាច់ប្រាក់ ត្រូវបានរៀបចំបង្កើតឡើងដោយឈរលើការអនុវត្តល្អបំផុតនិងផ្អែកតាមបញ្ញត្តិនិងការណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ លើសពីនេះទៅទៀត គណៈកម្មាធិការមួយអាចត្រូវបានរៀបចំ ឬបង្កើត ដើម្បីឆ្លើយតបការវិវត្តន៍របស់ខ្លួនក៏ដូចជាផលប៉ះពាល់ពីការវិវត្ត នៃសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ។

## ការបណ្តុះបណ្តាល និងការអភិវឌ្ឍ

ការបណ្តុះបណ្តាល និងអភិវឌ្ឍជាការងារស្នូល ដើម្បីជំរុញដល់អភិវឌ្ឍរបស់បុគ្គលិក និងការពេញចិត្តរបស់អតិថិជន។ ដូចនេះហើយបានជាយើងវិនិយោគលើជំនាញ និងការអភិវឌ្ឍរបស់បុគ្គលិក និងជ្រើសរើសនូវបុគ្គលិកប្រកបដោយជំនាញវិជ្ជាជីវៈ។ ជាការពិតការបំពេញតួនាទីប្រកបដោយវិជ្ជាជីវៈក្រមសីលធម៌ខ្ពស់ សុចរិតភាព និងភាពស្មោះត្រង់ គឺកំរិតស្នូលសំរាប់គ្រឹះស្ថានក្នុងការជំរុញ និងអនុវត្តនូវគោលការណ៍របស់ខ្លួន។ គ្រប់បុគ្គលិក និងអ្នកគ្រប់គ្រងទាំងអស់តម្រូវឱ្យអនុវត្តនូវភារៈកិច្ចរបស់ខ្លួនប្រកបដោយការទទួលខុសត្រូវ និងស្មោះត្រង់ ដោយតម្កល់នូវផលប្រយោជន៍របស់គ្រឹះស្ថាន និងការពេញចិត្តរបស់អតិថិជនជាចម្បង។



# គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបមិន ម.ក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)

លេខចុះបញ្ជីក្រុមហ៊ុនៈ 00024896

របាយការណ៍ហិរញ្ញវត្ថុ

សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

**ទំព័រ**

របាយការណ៍របស់ក្រុមប្រឹក្សាភិបាល ..... ........................................................................ ១
របាយការណ៍របស់សវនករឯករាជ្យ.............................................................................. ៤
របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ.......................................................................... ៩
របាយការណ៍ស្តីពីលទ្ធផលពេញលេញ.......................................................................... ១០
របាយការណ៍ស្តីពីបម្រែបម្រួលមូលធន......................................................................... ១១
របាយការណ៍ស្តីពីលំហូរសាច់ប្រាក់.............................................................................. ១៣
កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ ...................................................................... ១៥
ព័ត៌មានហិរញ្ញវត្ថុបន្ថែម និងកំណត់សម្គាល់ដែលតម្រូវដោយធនាគារជាតិនៃកម្ពុជា.................... i-v

*នេះមិនមែនផ្នែក នៃរបាយការណ៍សវនកម្មទេ

ក្រុមប្រឹក្សាភិបាលសូមបង្ហាញរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល រួមជាមួយរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ក្រុមហ៊ុន នាការិយបរិច្ឆេទ និងចុងការិយបរិច្ឆេទបញ្ចប់ត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០។

## ក្រុមប្រឹក្សាភិបាល

សមាសភាព នៃក្រុមប្រឹក្សាភិបាលដែលបានបម្រើការងារក្នុងកំឡុងឆ្នាំហិរញ្ញវត្ថុ និងរហូតដល់ចុងកាលបរិច្ឆេទ នៃរបាយការណ៍ នេះមានដូចខាងក្រោម៖

| | |
|---|---|
| លោក ម៉ែន សុខចំរើន | ប្រធានក្រុមប្រឹក្សាភិបាល |
| លោកស្រី Min Li | អភិបាល |
| លោកស្រី ង៉ូវ វួចងីម | អភិបាល (តែងតាំងនៅថ្ងៃទី២៨ ខែសីហា ២០២០) |

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលជាអ្នកទទួលខុសត្រូវដើម្បីធានាថារបាយការណ៍ហិរញ្ញវត្ថុផ្តល់នូវទិដ្ឋភាពពិត និង ត្រឹមត្រូវអំពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាចុងការិយបរិច្ឆេទថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ និងលទ្ធផលនៃប្រតិបត្តិការហើយ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុន។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះ ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនតម្រូវឱ្យ៖

ក) អនុម័តគោលនយោបាយគណនេយ្យសមស្របទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិកម្ពុជាសម្រាប់សហគ្រាស ធុនតូចនិង មធ្យម ("CIFRS សម្រាប់សហគ្រាសធុនតូច និងមធ្យម") ដែលតម្រូវឱ្យមានការវិនិច្ឆ័យ និងការប៉ាន់ស្មានដោយ សមហេតុផល ហើយបន្ទាប់មកត្រូវអនុវត្តគោលនយោបាយទាំងនោះជាអចិន្ត្រៃយ៍

ខ) អនុវត្តតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជាសំរាប់សហគ្រាសធុនតូច និងមធ្យម ឬប្រសិនបើមានគំលាតពីស្តង់ដារទាំងនេះដែលជាប្រយោជន៍ដល់ការបង្ហាញនូវភាពពិត និងត្រឹមត្រូវរបស់របាយការណ៍ហិរញ្ញវត្ថុ គំលាតទាំងនោះត្រូវបានបង្ហាញ ពន្យល់ឱ្យបានច្បាស់លាស់ និងកំណត់ចំនួនជាទឹកប្រាក់ក្នុងរបាយការណ៍ហិរញ្ញវត្ថុ

គ) រក្សាទុកនូវបញ្ជីការគណនេយ្យឱ្យបានត្រឹមត្រូវ និង ធានាការគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធិភាព។

## ទំនួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលចំពោះរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ឃ) រៀបចំរបាយការណ៍ហិរញ្ញវត្ថុផ្អែកលើមូលដ្ឋាននិរន្តភាព នៃដំណើរការអាជីវកម្ម លើកលែងតែក្នុងករណីដែលមានការសន្មត់ថាក្រុមហ៊ុននឹងមិនបន្តប្រតិបត្តិការនៅអនាគតដ៏ខ្លីនិង

ង) បង្កើតគោលនយោបាយទូទៅសំរាប់ក្រុមហ៊ុន អនុម័តរាល់ការសំរេចចិត្ត និងសកម្មភាពទាំងឡាយរបស់ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនដែលមានផលប៉ះពាល់ជាសារវន្តលើប្រតិបត្តិការអាជីវកម្ម និងលទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនហើយ ត្រូវធានាថាគោលនយោបាយ និងការសំរេចចិត្តទាំងអស់នោះត្រូវបានឆ្លុះបញ្ចាំង យ៉ាងពិតប្រាកដក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលក្រុមហ៊ុនបានធានាអះអាងថា ក្រុមហ៊ុនបានអនុវត្តទៅតាម លក្ខខ័ណ្ឌចាំបាច់នានាដូចដែលបានបញ្ជាក់ខាងលើ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ។

តាមគំនិតរបស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនត្រូវបានបង្កើតឡើងស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជាសំរាប់សហគ្រាសធុនតូចនិងមធ្យម ដើម្បីផ្តល់នូវទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងលទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ។

## ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ ក្រុមប្រឹក្សាភិបាលបានយកចិត្តទុកដាក់ទៅលើបញ្ហាដូចខាងក្រោម៖

ក) រាល់ការផ្ទេរជាសារវន្តទៅឬពីទុនបម្រុង ឬសំវិធានធនក្នុងឆ្នាំហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ខ) សំវិធានធនគ្រប់គ្រាន់សំរាប់ការខាតបង់លើ គណនីដែលត្រូវទទួល និង ទ្រព្យសកម្មនិងទ្រព្យសកម្មរយៈពេលវែងផ្សេងទៀត ត្រូវបានអនុវត្តបើសិនបើចាំបាច់។

គ) បំណុលអសារបង់ ត្រូវបានលុបចោល ប្រសិនបើមាន

ឃ) វិធីសាស្រ្តនៃការវាយតម្លៃទ្រព្យសកម្ម ឬបំណុលដែលមានស្រាប់ គឺមិនខុសឆ្គង ឬមិនសមរម្យ។

ង) មិនមានកាលៈទេសៈណាមួយដែលអាចដឹងពីចំនួនទឹកប្រាក់ណាក៏ដោយ ដែលបានបញ្ជាក់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុដែលនាំឱ្យមានការភាន់ច្រឡំ។

## ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ច) មិនមានគំលាតរវាងរបាយការណ៍ហិរញ្ញវត្ថុចុងការិយបរិច្ឆេទ ធៀបនឹង របាយការណ៍ក្នុងកាលបរិច្ឆេទនេះ ដូចជា ជាតុណាមួយ ប្រតិបត្តិការ ឬ ចំនុចសំខាន់ណាមួយដែលមានលក្ខណៈខុសប្រក្រតី ទៅតាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាលដែលនាំអោយប៉ះពាល់ដល់លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនសម្រាប់ក្នុងកំឡុងការិយបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុ ដែលរបាយការណ៍ពាយការណ៍នេះត្រូវបានធ្វើឡើង។

ឆ) លទ្ធផលនៃប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងកំឡុងពេលនៃឆ្នាំហិរញ្ញវត្ថុនេះ មិនត្រូវបានទទួលរងផលប៉ះពាល់ដោយជាតុណាមួយ ប្រតិបត្តិការ ឬ ចំនុចសំខាន់ណាមួយដែលមានលក្ខណៈខុសប្រក្រតី។

ជ) គ្មានយថាហេតុ ឬបំណុលផ្សេងទៀតរបស់ក្រុមហ៊ុនបានក្លាយទៅជាប្រតិបត្តិ ឬអាចនឹងត្រូវបានអនុវត្ត ក្នុងកំឡុងពេល ១២ខែ បន្ទាប់ពីការបញ្ចប់ឆ្នាំហិរញ្ញវត្ថុដែលក្នុងមតិយោបល់របស់ក្រុមប្រឹក្សាភិបាល នឹងមាន ឬអាចប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបំពេញកាតព្វកិច្ចរបស់ខ្លួននៅពេលដែលប្រតិបត្តិការនោះដល់ការកំណត់។

## ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ ដែលបានភ្ជាប់ជាមួយរបាយការណ៍នេះថាពិតជាបង្ហាញពីទិដ្ឋភាពពិត និងត្រឹមត្រូវពីស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ហើយនឹងលទ្ធផលនៃប្រតិបត្តិការ និងលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ទៅតាមស្តង់ដារហិរញ្ញវត្ថុអន្តរជាតិ នៃកម្ពុជាសំរាប់សហគ្រាសធុនតូច និងមធ្យម។

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន ភីជី ឌីវេឡុបម៉ិន ម.ក PG DEVELOPMENT PLC. KINGDOM OF CAMBODIA

លោក ម៉ែន សុខចំរើន
ប្រធានក្រុមប្រឹក្សាភិបាល

Crowe

**Crowe (KH) Co., Ltd.**

Unit 4B, 4th Floor, K1 Building
(#148), Mao Tse Tung Blvd, Sangkat
Toul Tumpung II, Khan Chamkar Morn,
Phnom Penh
Kingdom of Cambodia
Main +855 23 216 717
www.crowe.com.kh

**របាយការណ៍របស់សវនករឯករាជ្យសំរាប់សមាជិកនៃ**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គីជី ឌីវេឡុបមិុន ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុន: 00024896)

## ការរាយការណ៍លើរបាយការណ៍ហិរញ្ញវត្ថុ

## ទស្សនៈរបស់សវនករ

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គីជី ឌីវេឡុបមិុន ម.ក ហៅថា ("ក្រុមហ៊ុន") ដែលរួមមានរបាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ និងរបាយការណ៍ស្តីពីលទ្ធផលពេញលេញ របាយការណ៍ស្តីពីបម្រែបម្រួលមូលធន និងរបាយការណ៍ស្តីពីលំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ហើយនឹងគោលការណ៍គណនេយ្យសំខាន់ៗព្រមទាំងកំណត់សម្គាល់ផ្សេងទៀត ដែលមានចាប់ពីទំព័រទី០៩ ដល់ ទំព័រទី ៦៣។

តាមទស្សនៈរបស់យើងខ្ញុំរបាយការណ៍ហិរញ្ញវត្ថុនេះបង្ហាញនូវទិដ្ឋភាពពិតប្រាកដ និងត្រឹមត្រូវលើស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ ព្រមទាំងលទ្ធផលនៃប្រតិបត្តិការហិរញ្ញវត្ថុហើយនិង លំហូរសាច់ប្រាក់សំរាប់ការិយបរិច្ឆេទដែលបានបញ្ចប់ ដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសំរាប់សហគ្រាសធុនតូច និង មធ្យម។

### មូលដ្ឋាននៃទស្សនៈរបស់សវនករ

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិ។ ការទទួលខុសត្រូវរបស់ពួកយើងគឺ ស្ថិតនៅក្រោមស្តង់ដារដែលបានចែង និងរៀបរាប់នៅក្នុងផ្នែកទំនួលខុសត្រូវរបស់សវនករទៅលើរបាយការណ៍ហិរញ្ញវត្ថុនៃរបាយការណ៍សវនកម្មរបស់ពួកយើង។ យើងជឿជាក់ថាភស្តុតាងសវនកម្ម ដើម្បីពួកយើងប្រមូលបាន គឺគ្រប់គ្រាន់ និងសមហេតុផល ដើម្បីជាមូលដ្ឋានក្នុងការផ្តល់មតិយោបល់របស់យើងខ្ញុំ។

### ទំនួលខុសត្រូវរបស់សវនករឯករាជ្យ និងក្រមសីលធម៌

យើងខ្ញុំជាសវនករឯករាជ្យ ដែលតម្រូវឱ្យអនុលោមតាមក្រមសីលធម៌ ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុក្នុងព្រះរាជាណាចក្រកម្ពុជា។ ហើយយើងខ្ញុំ បានបំពេញនូវរាល់ទំនួលខុសត្រូវនានា ដែលតម្រូវដោយក្រមសីលធម៌នេះផងដែរ។

## របាយការណ៍របស់សវនករឯករាជ្យសំរាប់សមាជិកនៃ
## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តីជី ឌីវេឡុបម៉ិន ម.ក
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុនៈ 00024896)

### ព័ត៌មានបន្ថែមទៅលើរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករមានដូចតទៅនេះ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុន គឺជាអ្នកទទួលខុសត្រូវរាល់ព័ត៌មាន ដែលជាប់ពាក់ព័ន្ធជាមួយនឹងក្រុមហ៊ុន។ ព័ត៌មាននោះរួមបញ្ចូលទាំងរបាយការណ៍ក្រុមប្រឹក្សាភិបាល ប៉ុន្តែមិនបានរួមបញ្ចូលជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុននិងរបាយការណ៍របស់សវនករឡើយ។

ការបញ្ចេញទស្សនៈរបស់ពួកយើងទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គឺមិនបានរាប់បញ្ចូលជាមួយរបាយការណ៍ក្រុមប្រឹក្សាភិបាលឡើយ ហើយពួកយើងក៏មិនបានបង្ហាញជាលិខិតអះអាងទៅលើការសរុបមតិរបស់របាយការណ៍នោះផងដែរ។

ក្នុងការភ្ជាប់គ្នារវាងការធ្វើសវនកម្មទៅលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ចំពោះទំនួលខុសត្រូវរបស់សវនករ គឺគ្រាន់តែស្វែងយល់អំពី របាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងទទួលយករបាយការណ៍របស់ពួកគាត់ បើទោះបីជារបាយការណ៍របស់ក្រុមប្រឹក្សាភិបាលមានភាពមិនត្រឹមត្រូវទាក់ទងទៅ និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនក៏ដោយ ឬក៏មានភាពមិនប្រក្រតីចំពោះវិជ្ជាជីវៈរបស់សវនករដែលបានធ្វើសវនកម្ម ឬក៏ការកើតឡើងនូវភាពខុសប្រក្រតីណាមួយផ្សេងទៀត។

យោងទៅតាមការងារដែលពួកយើងបានបំពេញ ពួកយើងបានសន្និដ្ឋានថាវានឹងមានភាពមិនត្រឹមត្រូវទាក់ទងជាមួយរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល។ ហេតុដូចនេះ ហើយទើបបានជាពួកយើងទាមទារនូវរបាយការណ៍ដែលពិតប្រាកដ និងត្រឹមត្រូវ។ យើងខ្ញុំគ្មានអ្វី ដែលត្រូវរាយការណ៍ពីបញ្ហានេះទៀតឡើយ។

### ទំនួលខុសត្រូវរបស់អភិបាលទៅលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនជាអ្នកទទួលខុសត្រូវចំពោះការរៀបចំ និងការបង្ហាញទិដ្ឋភាពពិតប្រាកដនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនដោយអនុលោមទៅតាម ស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុ នៃកម្ពុជាសំរាប់ សហគ្រាសធុនតូច និងមធ្យម និងការណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលត្រូវទទួលខុសត្រូវដូចគ្នាផងដែរចំពោះប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ដែលក្រុមប្រឹក្សាភិបាលក្រុមហ៊ុនយល់ថាមានសារៈប្រយោជន៍ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុដែលពុំមានកំហុសឆ្គងជាសារវ័ន្ត ដែលបណ្តាលមកពីការក្លែងបន្លំ ឬ ការភាន់ច្រឡំ។

## របាយការណ៍របស់សវនករឯករាជ្យសំរាប់សមាជិកនៃ
## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គីជី ឌីវេឡុបម៉ិន ម.ក

(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុនៈ 00024896)

### ទំនួលខុសត្រូវរបស់អភិបាលទៅលើរបាយការណ៍ហិរញ្ញវត្ថុ (តពីទំព័រមុន)

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ត្រូវមានការទទួលខុសត្រូវរាល់សកម្មភាពរបស់ក្រុមហ៊ុន ដែលជានាអះអាងថា អាចមានលិទ្ធភាពបន្តក្នុងរយៈពេល១២ខែខាងមុខ និងរាល់បញ្ហា ដែលមានជាប់ពាក់ព័ន្ធជាមួយនឹងលិទ្ធភាពអាចបន្តរបស់ក្រុមហ៊ុន និងគោលបំណងដែលអាចធ្វើឱ្យមានសកម្មភាពនេះកើតឡើង ដែលតម្រូវឱ្យធ្វើការបង្ហាញទៅជាសាធារណៈ ដោយសារតែវាមានភាពចាំបាច់។ លើកលែងតែក្រុមប្រឹក្សាភិបាលណាមួយមានបំណងចង់ទូទាត់បំណុលរបស់ក្រុមហ៊ុនទាំងស្រុង ឬក៏អះអាងថានឹងបិទក្រុមហ៊ុន ហើយបើគ្មានសកម្មភាពណាមួយលេចឡើងនោះទេ យើងនៅតែត្រូវការរបាយការណ៍របស់ក្រុមប្រឹក្សាភិបាលដដែល។

### ទំនួលខុសត្រូវរបស់សវនករឯករាជ្យ

គោលបំណងរបស់យើងខ្ញុំ គឺដើម្បីទទួលបាននូវការធានាអះអាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងមូល នឹងមិនមានកំហុសឆ្គងជាសារវ័ន្ត មិនថាដោយសារការក្លែងបន្លំ ឬការភាន់ច្រឡំឡើយ។ ហើយធ្វើការរាយការណ៍របាយការណ៍សវនករ ដែលរាប់បញ្ចូលទាំងមតិយោបល់របស់យើងខ្ញុំផងដែរ។ ការធានាអះអាងដែលសមហេតុផល គឺការធានាអះអាងកម្រិតខ្ពស់ ប៉ុន្តែមិនមែនជានាអះអាងថាសវនកម្មដែលធ្វើឡើងស្របតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា តែងតែរកឃើញរាល់កំហុសជាសារវ័ន្តនោះឡើយ។ ការបំភាន់អាចកើតឡើងពីការក្លែងបន្លំ ឬកំហុសឆ្គង ហើយត្រូវបានគេចាត់ទុកថាជាសារវ័ន្ត ប្រសិនបើជាលក្ខណៈបុគ្គល ឬជាក្រុម ពួកវាអាចជះឥទ្ធិពលដល់ការសម្រេចចិត្តខាងសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដែលផ្អែកលើមូលដ្ឋាន នៃរបាយការណ៍ហិរញ្ញវត្ថុទាំងនេះ។

ជាផ្នែកមួយ នៃសវនកម្មស្របតាមស្តង់ដារអន្តរជាតិស្តីពីសវនកម្មនៃកម្ពុជា យើងអនុវត្តការវិនិច្ឆ័យប្រកបដោយវិជ្ជាជីវៈ និងរក្សាការសង្ស័យដែលមានជំនាញវិជ្ជាជីវៈ នៅសវនកម្មទាំងមូល។ យើងក៏:

ក). កំណត់ និងវាយតម្លៃហានិភ័យនៃភាពមិនត្រឹមត្រូវ ខាងសារវ័ន្ត នៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមិនថាដោយសារការក្លែងបន្លំ ឬកំហុស។ រៀបចំ និងអនុវត្តនីតិវិធីសវនកម្មឆ្លើយតបទៅនឹងហានិភ័យទាំងនោះ និងទទួលបានភស្តុតាងសវនកម្ម ដែលមានលក្ខណៈគ្រប់គ្រាន់នឹងសមស្រប ដើម្បីផ្តល់ជាមូលដ្ឋានសម្រាប់មតិយោបល់របស់យើង។ ហានិភ័យ ដែលមិនរកឃើញកំហុសខាងសារវ័ន្ត ដែលបណ្តាលមកពីការក្លែងបន្លំគឺមានភាពខ្ពស់ជាងបណ្តាលមកពីកំហុសឆ្គង ព្រោះការក្លែងបន្លំអាចពាក់ព័ន្ធនឹងការឃុបឃិត ការកែច្នៃ ការលុបចោលដោយចេតនាការ ការបកស្រាយមិនពិត ឬការបំពានក្នុងការគ្រប់គ្រងផ្ទៃក្នុង។

**របាយការណ៍របស់សវនករឯករាជ្យសំរាប់សមាជិកនៃ**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គីជី ឌីវេឡុបមិុន ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុនៈ 00024896)

**ទំនួលខុសត្រូវរបស់សវនករឯករាជ្យ(តពីទំព័រមុន)**

ខ). ទទួលបានការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធ នឹងសវនកម្មដើម្បីរៀបចំនីតិវិធីសវនកម្ម ដែលសមស្របក្នុងកាលៈទេសៈ ប៉ុន្តែមិនមែនសម្រាប់គោលបំណងនៃការបញ្ចេញមតិលើប្រសិទ្ធិភាព នៃការគ្រប់គ្រងផ្ទៃក្នុងរបស់ ក្រុមហ៊ុនឡើយ។

គ). វាយតម្លៃភាពសមស្រប នៃគោលនយោបាយគណនេយ្យ ដែលបានប្រើ និងភាពសមហេតុផល នៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញដែលពាក់ព័ន្ធដែលធ្វើឡើងដោយអ្នកគ្រប់គ្រង។

ឃ). សន្និដ្ឋានលើភាពសមស្រប នៃការប្រើប្រាស់របស់ក្រុមប្រឹក្សាភិបាល នៃមូលដ្ឋានដែលគួរឱ្យព្រួយបារម្ភ នៃគណនេយ្យ និងផ្អែកលើភស្តុតាងសវនកម្ម ដែលទទួលបានថាតើភាពមិនច្បាស់លាស់នៃសារវន្តមានទាក់ទងនឹង ព្រឹត្តិការណ៍ ឬលក្ខខណ្ឌ ដែលអាចធ្វើឱ្យមានការសង្ស័យយ៉ាងខ្លាំងចំពោះសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តភាពអាជីវកម្ម។ ប្រសិនបើយើងសន្និដ្ឋានថាមានភាពមិនច្បាស់លាស់នៃសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលទៅក្នុង របាយការណ៍របស់សវនកររបស់យើង ដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានហិរញ្ញវត្ថុ ឬបើការលាតត្រដាងព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិយោបល់សវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋាន របស់យើងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានរហូតដល់កាលបរិច្ឆេទ នៃរបាយការណ៍សវនកររបស់យើង។ ទោះយ៉ាងណា ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនបញ្ឈប់និរន្តភាពអាជីវកម្ម។

ង). វាយតម្លៃការបង្ហាញនៃទម្រង់ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនរួមមានការលាតត្រដាង និងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលតំណាងឱ្យប្រតិបត្តិការ និងព្រឹត្តិការណ៍មូលដ្ឋានក្នុងលក្ខណៈដែលទទួលបានការបង្ហាញដោយត្រឹមត្រូវ។

យើងបានផ្តល់ព័ត៌មានជូនអ្នកទទួលខុសត្រូវលើអភិបាលកិច្ចស្តីពីបញ្ហាផ្សេងៗ វិសាលភាព និងពេលវេលា ដែលបានគ្រោងទុកសម្រាប់ធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលមានរួមបញ្ចូលទាំងចំនុចខ្វះខាតក្នុងការគ្រប់គ្រងផ្ទៃក្នុង ដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្មរបស់យើង។

**របាយការណ៍របស់សវនករឯករាជ្យសំរាប់សមាជិកនៃ**
**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គីជី ឌីវេឡុបមុិន ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា )
( លេខចុះបញ្ជីក្រុមហ៊ុនៈ 00024896)

## បញ្ហាផ្សេងទៀត

ការធ្វើសវនកម្មរបស់យើងខ្ញុំ គឺក្នុងគោលបំណងបង្ហាញពីទស្សនៈទៅលើ មូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុទាំងមូលជារូបិយប័ណ្ណ ដុល្លារអាមេរិក។ ការបំលែងរបាយការណ៍ហិរញ្ញវត្ថុពីដុល្លារអាមេរិកទៅជាខ្មែររៀល ដោយប្រើអត្រាបិទនិងអត្រាមធ្យមនៅថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០ បានបង្ហាញឡើងក្នុងគោលបំណងវិភាគបន្ថែម ហើយមិនមែនជាផ្នែកសំខាន់នៃមូលដ្ឋានរបាយការណ៍ហិរញ្ញវត្ថុនោះទេ។ ការបំលែងនេះ មិនត្រូវបានធ្វើសវនកម្មទៅតាមនីតិវិធីដែលបានអនុវត្តទៅលើរបាយការណ៍ហិរញ្ញវត្ថុនោះទេ ហេតុដូច្នេះយើងខ្ញុំមិនបានបញ្ចេញទស្សនៈណាមួយទៅលើការបំលែងនេះឡើយ។

**Crowe (KH) Co., Ltd.**
ក្រុមហ៊ុនស្នងការគណនេយ្យករជំនាញ

**Onn Kien Hoe**
អភិបាល
ថ្ងៃទី២៩ ខែ ឧសភា ឆ្នាំ២០២០

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តីជី ឌីវេឡុបម៉ិន ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុន: 00024896)

## របាយការណ៍ស្តីពីស្ថានភាពហិរញ្ញវត្ថុ
នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០១៩ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល | ២០១៩ ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| **ទ្រព្យសកម្ម** | | | | | |
| សាច់ប្រាក់ក្នុងដៃ | ៥ | 925,850 | 971,013 | 3,745,063 | 3,956,878 |
| សមតុល្យនៅធនាគារជាតិ នៃកម្ពុជា | ៦ | 964,050 | 13,789 | 3,899,582 | 56,190 |
| ឥណទាន និងបុរេប្រទាន -- សុទ្ធ | ៧ | 500,108 | 539,138 | 2,022,937 | 2,196,987 |
| ទ្រព្យសកម្មផ្សេងៗ | ៨ | 6,820 | 8,027 | 27,587 | 32,710 |
| ប្រាក់តម្កល់តាមច្បាប់ នៅធនាគារជាតិ នៃកម្ពុជា | ៩ | 150,000 | 100,000 | 606,750 | 407,500 |
| ទ្រព្យ និងគ្រឿងបរិក្ខារ | ១០ | 15,647 | 39,133 | 63,292 | 159,467 |
| ទ្រព្យអរូបី | ១១ | - | 7,768 | - | 31,655 |
| **ទ្រព្យសកម្មសរុប** | | 2,562,475 | 1,678,868 | 10,365,211 | 6,841,387 |
| **បំណុល និង មូលធន** | | | | | |
| **បំណុល** | | | | | |
| បំណុលផ្សេងៗ | ១២ | 31,171 | 25,284 | 126,087 | 103,032 |
| បំណុលប្រាក់ពន្ធ | | 60 | 62 | 243 | 253 |
| **បំណុលសរុប** | | 31,231 | 25,346 | 126,330 | 103,285 |
| **មូលធន** | | | | | |
| ដើមទុន | ១៣ | 3,000,000 | 2,000,000 | 12,000,000 | 8,000,000 |
| ខាតបង្គរ | | (468,756) | (346,478) | (1,896,983) | (1,402,368) |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | - | 135,864 | 140,470 |
| **មូលធនសរុប** | | 2,531,244 | 1,653,522 | 10,238,881 | 6,738,102 |
| **បំណុល និង មូលធនសរុប** | | 2,562,475 | 1,678,868 | 10,365,211 | 6,841,387 |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ ភីជី ឌីវេឡុបម៉ិន ម.ក
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុនៈ 00024896)

## របាយការណ៍ស្តីពីលទ្ធផលពេញលេញ
សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២០

| | កំណត់សម្គាល់ | ០១.០១.២០២០ ទៅដល់ ៣១.១២.២០២០ ដុល្លារអាមេរិក | ០១.០១.២០១៩ ទៅដល់ ៣១.១២.២០១៩ ដុល្លារអាមេរិក | ០១.០១.២០២០ ទៅដល់ ៣១.១២.២០២០ ខ្មែរពាន់រៀល | ០១.០១.២០១៩ ទៅដល់ ៣១.១២.២០១៩ ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| ចំណូលការប្រាក់ | ១៤ | 63,920 | 47,056 | 258,556 | 190,671 |
| ចំណូលផ្សេងៗ | ១៥ | 3,598 | 5,021 | 14,554 | 20,345 |
| ចំណាយលើប្រាក់ខែបុគ្គលិក | ១៦ | (89,059) | (74,914) | (360,244) | (303,552) |
| រំលស់លើទ្រព្យរូបី | ១០ | (23,893) | (29,245) | (96,647) | (118,502) |
| រំលស់លើទ្រព្យអរូបី | ១១ | (7,768) | (11,634) | (31,422) | (47,141) |
| ចំណាយលើប្រតិបត្តិការផ្សេងៗ | | (64,832) | (57,736) | (262,245) | (233,945) |
| លទ្ធផលពីប្រតិបត្តិការមុនសំវិធានធន | | (118,034) | (121,452) | (478,135) | (492,124) |
| សំវិធានធនសំរាប់ឥណទាន និងបុរេប្រទាន | ៧ | (3,434) | (1,594) | (13,891) | (6,459) |
| ខាតមុនបង់ពន្ធ | | (121,468) | (123,046) | (491,339) | (498,583) |
| ចំណាយពន្ធលើប្រាក់ចំនេញ | ១៧ | (810) | (521) | (3,276) | (2,111) |
| ខាតបន្ទាប់ពីបង់ពន្ធ | | (122,278) | (123,567) | (494,615) | (500,694) |

## គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ តឹជី ឌីវេឡុបម៉ិន ម.ក
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុនៈ 00024896)

## របាយការណ៍ស្តីពីបម្រែបម្រួលមូលធន
សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់សម្គាល់ | មូលធន<br>ដុល្លារអាមេរិក | ខាតបង្គរ<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ ២០១៨/ ១ ខែ មករា ឆ្នាំ ២០១៩ | | 2,000,000 | (222,911) | 1,777,089 |
| ខាតបន្ទាប់ពីបង់ពន្ធសម្រាប់ការិយបរិច្ឆេទ | | - | (123,567) | (123,567) |
| សមតុល្យថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩/ ១ ខែ មករា ឆ្នាំ ២០២០ | | 2,000,000 | (346,478) | 1,653,522 |
| ទុនបន្ថែម | | 1,000,000 | - | 1,000,000 |
| ខាតបន្ទាប់ពីបង់ពន្ធសម្រាប់ការិយបរិច្ឆេទ | | - | (122,278) | (122,278) |
| សមតុល្យថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | | 3,000,000 | (468,756) | 2,531,244 |

| | កំណត់សម្គាល់ | មូលធន<br>ខ្មែរពាន់រៀល | ខាតបង្គរ<br>ខ្មែរពាន់រៀល | ទឹកប្រាក់លំអៀងបង្គរពីការប្តូរប្រាក់<br>ខ្មែរពាន់រៀល | សរុប<br>ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| សមតុល្យថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៨/ ថ្ងៃទី១ ខែ មករា ឆ្នាំ ២០១៩ | | 8,000,000 | (901,674) | 42,018 | 7,140,344 |
| ទុនបន្ថែម | | - | - | - | - |
| ខាតបន្ទាប់ពីបង់ពន្ធសម្រាប់ការិយបរិច្ឆេទ | | - | (500,694) | - | (500,694) |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | - | 98,452 | 98,452 |
| សមតុល្យថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០១៩/ ថ្ងៃទី១ ខែមករា ឆ្នាំ ២០២០ | | 8,000,000 | (1,402,368) | 140,470 | 6,738,102 |
| ទុនបន្ថែម | | 4,000,000 | - | - | 4,000,000 |
| ខាតបន្ទាប់ពីបង់ពន្ធសម្រាប់ការិយបរិច្ឆេទ | | - | (494,615) | - | (494,615) |
| លំអៀងពីអត្រាប្តូរប្រាក់ | | - | - | (4,606) | (4,606) |
| សមតុល្យថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០ | | 12,000,000 | (1,896,983) | 135,864 | 10,238,881 |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គីជី ឌីវេឡុបម៉ិន ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុនៈ 00024896)

## របាយការណ៍ស្តីពីលំហូរសាច់ប្រាក់
សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់សម្គាល់ | ២០២០<br>ដុល្លារអាមេរិក | ២០១៩<br>ដុល្លារអាមេរិក | ២០២០<br>ខ្មែរពាន់រៀល | ២០១៩<br>ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពីសកម្មភាពប្រតិបត្តិការ** | | | | | |
| ខាតមុនការបង់ពន្ធ | | (121,468) | (123,046) | (491,339) | (498,583) |
| និយ័តភាពៈ | | | | | |
| ការធ្វើសំវិធានធនលើៈ | | | | | |
| -ឥណទាន និងបុរេប្រទាន | ៧ | 3,434 | 1,594 | 13,891 | 6,459 |
| រំលស់លើទ្រព្យ និងគ្រឿងបរិក្ខារនិងទ្រព្យអរូបី | | 31,661 | 40,879 | 128,069 | 165,642 |
| ខាតមុនបម្រែបម្រួលទុនបង្វិល | | (86,373) | (80,573) | (349,379) | (326,482) |
| បម្រែបម្រួលទុនបង្វិលៈ | | | | | |
| - ឥណទាន និងបុរេប្រទានទៅកាន់អតិថិជន | | 35,596 | (159,435) | 143,986 | (649,698) |
| - ទ្រព្យសកម្មផ្សេងៗ | | 1.207 | (502) | 4,883 | (2,046) |
| - សមតុល្យនៅធនាគារជាតិ នៃកម្ពុជា | | - | 23,160 | - | 94,377 |
| -ប្រាក់តម្កល់តាមច្បាប់ នៅធនាគារជាតិ នៃកម្ពុជា | | (50,000) | - | (202,250) | - |
| - បំណុលផ្សេងៗ | | 5,887 | 1,676 | 23,813 | 6,830 |
| **សាច់ប្រាក់ដែលត្រូវបានប្រើក្នុង សកម្មភាពប្រតិបត្តិការ** | | (93,683) | (215,674) | (378,947) | (877,019) |
| ពន្ធប្រាក់ចំណេញដែលត្រូវបង់ | ១៧ | (812) | (509) | (3,285) | (2,062) |
| **សាច់ប្រាក់ដែលត្រូវបានប្រើក្នុងសកម្មភាព ប្រតិបត្តិការសុទ្ធ** | | (94,495) | (216,183) | (382,232) | (879,081) |
| **លំហូរសាច់ប្រាក់ពីសកម្មភាពវិនិយោគ** | | | | | |
| ការទិញគ្រឿងបរិក្ខារ | ១០ | (407) | - | (1,646) | - |
| ការទិញទ្រព្យអរូបី | ១១ | - | - | - | - |
| **សាច់ប្រាក់សុទ្ធដែលត្រូវបានក្នុងសកម្មភាពវិនិយោគ** | | (407) | - | (1,646) | - |

**គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ គីជី ឌីវេឡុបមិន ម.ក**
(បង្កើតក្នុងព្រះរាជាណាចក្រកម្ពុជា)
(លេខចុះបញ្ជីក្រុមហ៊ុន: 00024896)

**របាយការណ៍ស្តីពីលំហូរសាច់ប្រាក់**
សំរាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ២០២០

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០១៩ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល | ២០១៩ ខ្មែរពាន់រៀល |
|---|---|---|---|---|---|
| **លំហូរសាច់ប្រាក់ពី/(សម្រាប់) សកម្មភាព ហិរញ្ញប្បទាន** | | | | | |
| ភាគហ៊ុន | | 1,000,000 | - | 4,000,000 | - |
| **លំហូរសាច់ប្រាក់សុទ្ធពីសកម្មភាព ហិរញ្ញប្បទាន** | | 1,000,000 | - | 4,000,000 | - |
| **ការកើនឡើងសាច់ប្រាក់សុទ្ធ** | | 905,098 | (216,183) | 3,616,122 | (879,081) |
| **សាច់ប្រាក់នៅដើមការិយបរិច្ឆេទក្នុងឆ្នាំ** | | 971,013 | 1,200,985 | 4,013,068 | 4,825,558 |
| **បម្រែបម្រួលអត្រាប្តូរប្រាក់** | | - | - | 15,455 | 66,591 |
| **សាច់ប្រាក់ចុងគ្រា** | | 1,889,900 | 984,802 | 7,644,645 | 4,013,068 |

(i) សាច់ប្រាក់និងសមមូលសាច់ប្រាក់ដែលបានបញ្ចូលក្នុងរបាយការណ៍លំហូរសាច់ប្រាក់រួមមានដូចខាងក្រោមនេះ៖

| | កំណត់សម្គាល់ | ២០២០ ដុល្លារអាមេរិក | ២០១៩ ដុល្លារអាមេរិក | ២០២០ ខ្មែរពាន់រៀល | ២០១៩ ខ្មែរពាន់រៀល |
|---|---|---|---|---|---|
